**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ

លេខ ..០០៩ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១០

# សេចក្តីណែនាំ
## ស្តីពី
## ការគ្រប់គ្រងវត្តមានជនបរទេស ក្នុងព្រះរាជាណាចក្រកម្ពុជា

កន្លងទៅនេះ ក្រសួងមហាផ្ទៃ បានចេញសេចក្តីជូនដំណឹងលេខ ៩៣៦ សជណ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៥ និងសេចក្តីជូនដំណឹងលេខ ៣៥៦ សជណ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការជូនដំណឹងអំពីវត្តមានជនបរទេសស្នាក់នៅតាមលំនៅដ្ឋាន ទីតាំងអាជីវកម្ម និងមិនអាជីវកម្ម គ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងអនុវត្តមាត្រា ១៨ នៃច្បាប់ស្តីពីអន្តោប្រវេសន៍អោយមានប្រសិទ្ធភាព ។

ក្រោយពេលចេញសេចក្តីជូនដំណឹងទាំងពីរខាងលើរួចមក ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា មានអ្នកកាន់កាប់លំនៅដ្ឋាន ទីតាំងអាជីវកម្ម និងមិនអាជីវកម្មគ្រប់ប្រភេទ ភាគច្រើនបានអនុវត្តតាមសេចក្តីជូនដំណឹង ដោយស្មារតីភ្ញាក់រលឹករួសរាន់និងការទទួលខុសត្រូវខ្ពស់ ប៉ុន្តែនៅមានអ្នកកាន់កាប់លំនៅដ្ឋាន ទីតាំងអាជីវកម្ម និងមិនអាជីវកម្មមួយចំនួន មិនទាន់យល់អំពីកាតព្វកិច្ច និងអនុវត្តភារកិច្ចរបស់ខ្លួនអោយបានច្បាស់លាស់នៅឡើយ ។

ដើម្បីសំដៅបង្កើនការគ្រប់គ្រងវត្តមានជនបរទេស និង កិច្ចការរដ្ឋបាលអោយមានប្រសិទ្ធភាពខ្ពស់ ធានាបាននូវសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព ជូនជនបរទេសគ្រប់រូបដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃ សូមធ្វើសេចក្តីណែនាំដូចខាងក្រោម :

១-អ្នកកាន់កាប់ លំនៅដ្ឋាន ទីតាំងអាជីវកម្ម និងមិនអាជីវកម្មគ្រប់ប្រភេទ ត្រូវរាយការណ៍អំពីវត្តមានជនបរទេស ដែលបានចូលមកស្នាក់នៅក្នុងទីតាំងរបស់ខ្លួន ដល់នគរបាលប៉ុស្តិ៍រដ្ឋបាល នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត មិនអោយលើសពីរយៈពេល ២៤ម៉ោង ។

២-ក្នុងករណីអ្នកកាន់កាប់លំនៅដ្ឋាន ទីតាំងអាជីវកម្ម និងមិនអាជីវកម្មគ្រប់ប្រភេទជាជនបរទេស ត្រូវរាយការណ៍អំពីវត្តមានរបស់ខ្លួនឯង និងសមាជិកក្នុងបន្ទុករបស់ខ្លួនតាំងពីថ្ងៃចាប់ផ្តើមធ្វើអាជីវកម្ម និងថ្ងៃចូលមកស្នាក់នៅ ។

៣-ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវផ្តល់គំរូសេចក្តីរាយការណ៍អំពីវត្តមានជនបរទេសដែលចេញដោយនាយកដ្ឋានអន្តោប្រវេសន៍ ផ្តល់ជូនទៅម្ចាស់លំនៅដ្ឋាន ទីតាំងអាជីវកម្ម និងមិនអាជីវកម្មគ្រប់ប្រភេទ

ដើម្បីធ្វើសេចក្តីរាយការណ៍ប្រចាំថ្ងៃដល់ប៉ុស្តិ៍នគរបាលរដ្ឋបាល និង ត្រូវបូកសរុបរាយការណ៍ផ្ញើមកនាយកដ្ឋានអន្តោប្រវេសន៍រៀងរាល់ថ្ងៃ ។

៤-អ្នកកាន់កាប់លំនៅដ្ឋាន ទីតាំងអាជីវកម្ម និងមិនអាជីវកម្មគ្រប់ប្រភេទ ត្រូវរាយការណ៍អំពីការផ្លាស់ប្តូរ ការបន្តស្នាក់នៅ និងរាល់ឧប្បត្តិហេតុនានាលើជនបរទេស ជូនកម្លាំងមានសមត្ថកិច្ចជាបន្ទាន់ ដើម្បីមានវិធានការសមស្រប និងទាន់ពេលវេលា ។

៥-ចំពោះអ្នកកាន់កាប់លំនៅដ្ឋាន ទីតាំងអាជីវកម្ម និងមិនអាជីវកម្មគ្រប់ប្រភេទណា ដែលមិនបានរាយការណ៍អំពីវត្តមានជនបរទេសតាមការកំណត់ នៃសេចក្តីណែនាំនេះ នឹងត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ផ្សេងៗទៀត នៃព្រះរាជាណាចក្រកម្ពុជា ។

៦-ក្រសួងមហាផ្ទៃ សូមអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូប មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ កងកម្លាំងមានសមត្ថកិច្ចគ្រប់ប្រភេទ ត្រូវរួមចំណែកផ្តល់ព័ត៌មាន និង រាយការណ៍ដល់សមត្ថកិច្ចពាក់ព័ន្ធ អំពីវត្តមានជនបរទេស ដែលស្នាក់នៅក្នុង មូលដ្ឋានរបស់ខ្លួន ។

៧-អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវធ្វើផែនការសកម្មភាពលំអិតមួយ ណែនាំដល់កងកំលាំងនគរបាលជាតិទាំងមូល ដើម្បីអនុវត្តសេចក្តីណែនាំនេះ។

៨-ទទួលបានសេចក្តីណែនាំនេះ ឯកឧត្តមអភិបាលរាជធានី-ខេត្ត លោកស្នងការនគរបាលរាជធានី-ខេត្ត ត្រូវធ្វើការផ្សព្វផ្សាយ អប់រំ ណែនាំដល់មន្ត្រី និងប្រជាពលរដ្ឋ ដើម្បីចាត់តាំងអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**ចំលងជូន**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- -ក្រសួងទេសចរណ៍
- -អគ្គស្នងការដ្ឋាននគរបាលជាតិ
- -អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
- -សាលារាជធានី-ខេត្ត
- -ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- -ឯកសារ-កាលប្បវត្តិ .